វគ្គបំប៉នថ្នាក់ទី១២

# ប្រធានអត្ថាធិប្បាយពន្យល់ទូទៅ
# ប្រធានទី៤

វ៉ាន់ វី
សាស្ត្រាចារ្យជំនួយ
នៅដេប៉ាតឺម៉ង់ភាសាវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៩ មិថុនា ២០២៤

# មាតិកា

- ប្រធានទី៤
- គម្រោងតែង
- សេចក្តីអធិប្បាយ

**ប្រធានទី៤៖** គេពោលថា “បើមានតែទ្រព្យសម្បត្តិមួយមុខមិនគ្រប់គ្រាន់ទេ លុះត្រាតែមានចំណេះប្រាជ្ញាទៀតទើបអាចគ្រប់គ្រាន់”។ ចូរពន្យល់ដោយលើកឧទាហរណ៍ពីក្នុងសង្គមនិងអក្សរសិល្ប៍មកបញ្ជាក់ផង។

# គម្រោងតែង

១- សេចក្ដីផ្ដើម

- លំនាំបញ្ហា
- ចំណូលបញ្ហា
- ចំណោទបញ្ហា

២- តួសេចក្ដី

- ឃ្លាភ្ជាប់សេចក្ដី + ពន្យល់ពាក្យគន្លឹះ + ពន្យល់ន័យប្រធាន
- បកស្រាយប្រធាន៖ គំនិតសំខាន់និងអំណះអំណាង
- សរុប

៣- សេចក្ដីបញ្ចប់

- វាយតម្លៃប្រធាន
- មតិផ្ទាល់ខ្លួន

# សេចក្ដីអធិប្បាយ

មនុស្សយើងកើតមកក្នុងលោកសន្និវាសនេះ   រមែងប្រាថ្នាចង់មានវាសនារស់នៅដោយមានទ្រព្យធនសម្បូរសប្បាយ។ ប៉ុន្តែ មានត្រឹមតែទ្រព្យសម្បត្តិ ពុំទាន់គ្រប់គ្រាន់អាចឱ្យមនុស្សរស់នៅបានជាសុខ និងមានកេរ្តិ៍ឈ្មោះថ្លៃថ្នូរបានឡើយ គឺទាល់តែមានចំណេះដឹងថែមទៀត។ អាស្រ័យដូចនេះហើយ ទើបមានទស្សនៈមួយពោលថា “បើមានតែទ្រព្យសម្បត្តិមួយមុខមិនគ្រប់គ្រាន់ទេ លុះត្រាតែមានចំណេះប្រាជ្ញាទៀតទើបអាចគ្រប់គ្រាន់”។

តើពំនោលខាងលើនេះមានអត្ថន័យយ៉ាងណាខ្លះ?

មុននឹងស្រាយបំភ្លឺរកអត្ថន័យនៃពាក្យនៅលខាងលើថាមានន័យយ៉ាងណានោះ យើងគួរយល់ន័យរបស់ពាក្យមួយចំនួនសិន។ ពាក្យ "ទ្រព្យសម្បត្តិ" សំដៅទៅលើ ទ្រព្យធន ទ្រព្យរបស់សម្រាប់ប្រើប្រាស់ ឬធនធានសព្វសារពើ ដែលជាតម្រូវការរបស់មនុស្ស។ ចំណែកពាក្យ "ចំណេះប្រាជ្ញា" មានន័យថា ការចេះដឹងនិងបញ្ញាញាណសម្រាប់ត្រិះរិះពិចារណា។ ប្រធានខាងលើចង់បានសេចក្តីថា បើមានតែធនធាន ទ្រព្យរបស់សម្រាប់ប្រើប្រាស់មួយមុខ គឺមិនគ្រប់គ្រាន់នៅឡើយទេ ទាល់តែមានការចេះដឹងនិងបញ្ញាញាណសម្រាប់ត្រិះរិះពិចារណាផង ទើបជីវិតប្រសើរ។

ពិតមែនហើយ ទ្រព្យសម្បត្តិមានសារៈសំខាន់សម្រាប់មនុស្ស ព្រោះយើងត្រូវការវាដើម្បីបំពេញតម្រូវការក្នុងជីវិតរស់នៅ តែបើមានត្រឹមតែទ្រព្យធន ក៏ពុំទាន់គ្រប់គ្រាន់ដែរ។ នៅក្នុងសង្គមយើងសង្កេតឃើញថា បុគ្គលណាម្នាក់មានតែទ្រព្យ ពុំមានចំណេះដឹង ដើម្បីគ្រប់គ្រងរក្សា និងស្វែងរកទ្រព្យមកបន្ថែមទេ ទ្រព្យចាស់នោះក៏រលស់អស់ទៅតាមពេលវេលា។ ម្យ៉ាង បើមានតែទ្រព្យមួយមុខក៏មិនប្រាកដថា មានកេរ្តិ៍ឈ្មោះប្រសើរក្នុងសង្គមដែរ កាលបើពុំបានយកទ្រព្យនោះទៅប្រើឱ្យមានប្រយោជន៍សម្រាប់អភិវឌ្ឍសង្គម។ យ៉ាងណាមិញ បើប្រទ្បេកមកមើលអក្សរសិល្ប៍វិញម្តងយើងនឹងឃើញថា មានទ្រព្យតែមុខគឺមិនគ្រប់គ្រាន់ទេ។ ក្នុងរឿងឪពុកក្មេករើសកូនប្រសា តាដែលត្រូវជាឪពុកក្មេកមានទ្រព្យ តែគ្មានចំណេះធ្វើឱ្យគាត់ចាញ់ប្រាជ្ញាកំលោះទីពីរជាច្រើនលើក។ ចំណែករឿងធនញ្ជ័យវិញ ក៏ដូច្នោះដែរ មិនថាសេដ្ឋី ឬព្រះរាជាទេ សុទ្ធតែត្រូវចាញ់ប្រាជ្ញារបស់ធនញ្ជ័យដែលជាកូនកសិករ។ ដោយឡែក តាមរយៈរឿងថៅកែចិត្តចោរ អ្នកនិពន្ធចង់បង្ហាញថា ទោះថៅកែមានសម្បត្តិច្រើនក្តី ក៏មិនទទួលបានការគោរពនិងទំនុកចិត្តពីកម្មករដែរ ដ្បិតគាត់បានជួលពូហំឱ្យទៅប្រព្រឹត្តខុសច្បាប់ ថែមទាំងគេងប្រវ័ញ្ចកម្លាំងកម្មករ និងសូកប៉ាន់នគរបាលទៀត។

ដើម្បីឱ្យជីវិតពេញបរិបូណ៌ មានត្រឹមតែទ្រព្យធនម្យ៉ាង គឺមិនទាន់គ្រប់គ្រាន់ទេ ចាំបាច់ត្រូវមានចំណេះប្រាជ្ញាទៀត។ ចំណេះវិជ្ជាសំខាន់សម្រាប់មនុស្សគ្រប់រូប ព្រោះជាស្ពានចម្លងគេឱ្យផុតពីសេចក្ដីល្ងង់ខ្លៅ ភាពក្រីក្រ និងឆ្ពោះទៅរកសុភមង្គល។ កាលណាមានចំណេះដឹងហើយ គេក៏មានសមត្ថភាពអាចប្រកបការងារសម្រាប់ចិញ្ចឹមជីវិតបាន ដូចពាក្យគេច្រើនពោលថា "ចំណេះជាអាហារ"។ ដោយសារតែចំណេះវិជ្ជាទើបធ្វើឱ្យមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការកសាងខ្លួនឯង គ្រួសារ និងសង្គមជាតិឱ្យរីកចម្រើន។ ជាតឹកតាង បើយើងសង្កេតមើលសង្គមជាក់ស្ដែង គង់ឃើញថា បណ្ដាប្រទេសអភិវឌ្ឍនានាអាចចម្រើនរុងរឿងបាន ក៏ដោយសារតែមានប្រជាពលរដ្ឋប្រកបដោយចំណេះដឹងជ្រៅជ្រះ ជាធនធានសម្រាប់កសាងនិងអភិវឌ្ឍជាតិ មានប្រទេសសិង្ហបុរី ជប៉ុន និងសហរដ្ឋអាមេរិក ជាដើម។ ដោយឡែក បើពិនិត្យមើលស្នាដៃអក្សរសិល្ប៍ខេមរនិយមរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ របស់លោក សួន សុរិន្ទ ក៏នឹងឃើញជាក់ថា វិជ្ជាមានតម្លៃណាស់សម្រាប់កសាងសង្គមជាតិ។ នៅត្រង់វគ្គ "ទីពឹងថ្មី" អ្នកនិពន្ធបានបង្ហាញថា លោករដ្ឋមន្ត្រីថ្មីមានចំណេះដឹងខ្ពង់ខ្ពស់ ដោយលោកបានបញ្ចប់ការសិក្សាមកពីបរទេស។ លោកបានវិលមកមាតុភូមិវិញ ក្នុងបំណងជួយអភិវឌ្ឍប្រទេសជាតិ។

ក្រៅពីនេះ ចំណេះដឹងក៏ដឹកនាំមនុស្សឱ្យក្លាយជាបុគ្គលមានកិត្តិយស មានកេរ្តិ៍ឈ្មោះ ដែលមានគេឯងគោរពស្រឡាញ់ច្រើនក្នុងសង្គម។ ជាក់ស្តែង អ្នកប្រាជ្ញ កវី អ្នកនិពន្ធ សិល្បករនានា ដែលមានកេរ្តិ៍ឈ្មោះល្បីក្នុងសង្គម គឺដោយសារអ្នកទាំងនោះមានចំណេះជ្រៅជ្រះ និងមានការប៉ិនប្រសប់ទៅតាមមុខជំនាញរបស់ខ្លួន។ បើពិនិត្យមើលស្នាដៃអក្សរសិល្ប៍ខ្មែរមួយចំនួន យើងគង់ឃើញថា ចំណេះវិជ្ជាមានតម្លៃណាស់សម្រាប់ជីវិតមនុស្ស។ ក្នុងស្នាដៃអក្សរសិល្ប៍ព្រាហ្មណ៍និយមរឿងរាមកេរ្តិ៍ អ្នកនិពន្ធបានបង្ហាញពីខ្សែជីវិតរបស់ព្រះរាមដែលជាតួអង្គមានកិត្តិនាមល្បីល្បាញ ដោយសារព្រះអង្គមានថ្វីដៃក្នុងការបង្ក្រាបសភាវៈអាក្រក់។ ទ្រង់មានចំណេះ ដោយសារតែបានសិក្សាចេះចប់គម្ពីរត្រៃវេទក្នុងសំណាក់ឥសីពិស្វាមិត្រ។ ចំណែករឿងកុលាបប៉ៃលិន របស់លោក ញ៉ុម ថែម ក៏បានលាតត្រដាងដែរថា ដោយសារចៅចិត្រមានចំណេះប្រាជ្ញា ទើបញ៉ាំងឱ្យចៅចិត្រទទួលបានការទុកចិត្តពីហ្លួងរតនៈសម្បត្តិ និងនាងឃុននារី។ ទីបំផុតចៅចិត្រទទួលបាននាងឃុននារីជាភរិយាបន្តតំណែងពីលោកហ្លួងរតនៈសម្បត្តិ រស់នៅប្រកបដោយក្តីសុខក្សេមក្សាន្ត។

មិនតែប៉ុណ្ណោះ ចំណេះវិជ្ជាក៏ជាចំណែកមួយជួយកសាងបុគ្គលិកលក្ខណៈមនុស្សឱ្យកាន់តែប្រពៃ គឺឱ្យមានសីលធម៌ គុណធម៌ សុជីវធម៌ក្នុងការរស់នៅ។ ក្នុងសង្គមជាក់ស្តែង បើបុគ្គលណាមានតែទ្រព្យ ហើយខ្វះនូវធម៌ទាំងនេះក្នុងខ្លួន ច្បាស់ជាគ្មាននរណាគេគោរពស្រឡាញ់និងឱ្យតម្លៃឡើយ។ បើពិនិត្យមើលអក្សរសិល្ប៍រឿងកុលាបប៉ៃលិន ក៏ឃើញដូច្នោះដែរ គឺ លោកហ្លួងរតនសម្បត្តិ ពុំមែនមានត្រឹមតែមានសម្បត្តិច្រើនសន្ធឹកសន្ធាប់ទេ លោកថែមទាំងទឹកចិត្តល្អ មានធម៌សន្តោសប្រណីដ៏ប្រពៃក្នុងខ្លួនទៀតផង។ ហេតុនេះហើយបានជា កម្មករត្បូងទាំងអស់គោរពស្រឡាញ់ និងហ៊ានលះបង់ជីវិតការពារលោកនិងក្រុមគ្រួសារ។

រួមសេចក្ដីមក ទ្រព្យធនតែមួយមុខពុំគ្រប់គ្រាន់ឡើយ គឺទាល់តែមានចំណេះដឹង និងបញ្ញាញាណសម្រាប់ត្រិះរិះពិចារណាផង ទើបជីវិតប្រព្រឹត្តទៅបានល្អប្រសើរ។

ឆ្លងតាមការបកស្រាយរួចមក យើងឃើញថា ពំនោលខាងលើពិតជាមានអត្ថន័យល្អ ព្រោះបានអប់រំយើងឱ្យលើកតម្លៃចំណេះវិជ្ជា ពុំមែនឱ្យគិតត្រឹមតែតម្លៃទ្រព្យធនប៉ុណ្ណោះទេ។ ទ្រព្យធនអាចរលាយបាត់បង់បាន ប៉ុន្តែបើយើងមានទ្រព្យសម្បត្តិហើយមានចំណេះវិជ្ជាជាគ្រឹះទៀតនោះ នឹងធ្វើឱ្យយើងបានថ្កុំថ្កើងក្នុងជីវិតរស់នៅ។ ដូច្នេះ យើងជាយុវជនគប្បីខិតខំព្យាយាមសិក្សាក្រេបយកចំណេះដឹងឱ្យបានច្រើន ដើម្បីយកទៅកសាងខ្លួនឯង គ្រួសារ និងសង្គមជាតិឱ្យរីកលូតលាស់។

# ឯកសារពិគ្រោះ


កាន់ ចាន់ដារ៉ា និង វ៉ាន់ វី *តែងសេចក្តី៖ ប្រធានពន្យល់* ភ្នំពេញ ឆ្នាំ២០១២។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្តី*** *(សម្រាប់មធ្យមសិក្សាទុតិយភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្តី*** *(សម្រាប់មធ្យមសិក្សាបឋមភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

សែម សូរ, ថោង ផែល និងអ្នកដទៃទៀត ***វិញ្ញាសាតែងសេចក្តីគំរូ*** បណ្ណាគារមាយើង ឆ្នាំ១៩៧១។

**ប្រធានទី៥៖** ពាក្យទូន្មានមួយឃ្លាពោលថា "កូនកាចបំពេញទុក្ខ ម្ដាយឪពុកព្រួយបារម្ភ កូនស្លូតចេះគួរសម មេបាថ្កុំថ្កើងកេរ្ដិ៍ឈ្មោះ"។ ចូរពន្យល់ដោយឆ្លុះបញ្ចាំងតាមរយៈសង្គម និងអក្សរសិល្ប៍ដែលអ្នកធ្លាប់បានសិក្សាកន្លងមក។